**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តស្វាយរៀង**
លេខ ០៤២/២០ ស.ជ.ណ

ថ្ងៃសុក្រ ១៥កើត ខែ អស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ស្វាយរៀង, ថ្ងៃទី ០២ ខែ តុលា ឆ្នាំ២០២០

# សេចក្តីជូនដំណឹង
## ស្តីពី
## ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការ ឆ្នាំ២០២១

-យោងសេចក្តីសម្រេច០៩៧ សសរ/គ.ជ.អ.ប ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០១៧ ស្តីពីការដាក់ឲ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិ ឃុំ សង្កាត់ អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការមានសិទ្ធិដាក់សំណើដេញថ្លៃ នៅគ្រប់គម្រោងមូលនិធិឃុំ សង្កាត់។ ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

-យោងសេចក្តីជូនដំណឹងលេខ០៨៨ សជណ/គ.ជ.អ.បចុះថ្ងៃទី៧ ខែ កញ្ញាឆ្នាំ២០២០ស្តីពីការរៀបចំបញ្ជីឈ្មោះអ្នកទទួលការលទ្ធកម្មគម្រោងមូលនិធិឃុំសង្កាត់ឆ្នាំ២០២១របស់គណៈកម្មាធិការជាតិសម្រាប់កាអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

រដ្ឋបាលខេត្តស្វាយរៀងនឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០២១ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០២១។

អ្នកទទួលការត្រូវបានបែងចែកជា០៣ប្រភេទ ៖

- ប្រភេទទី១ ៖ អ្នកទទួលការសំណង់ទូទៅ (ការងារសំណង់អគារ និងការងារបេតុង ...។ល។)
- ប្រភេទទី២ ៖ អ្នកទទួលការការងារដី (ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវក្រួសក្រហម ...។ល។)
- ប្រភេទទី៣៖អ្នកទទួលការឯកទេស (អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេសសម្រាប់ការងារពិសេស ឧទាហរណ៍ អណ្តូងស្នប់ ...។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារបរិក្ខារគ្រប់គ្រាន់ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ ហើយត្រូវមានបទពិសោធន៍អនុវត្តគម្រោងទាក់ទងទៅនឹងប្រភេទនីមួយៗដែលបានស្នើសុំយ៉ាងតិច០២គម្រោង ក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយ។ អនុគណៈកម្មការបុរេលក្ខណសម្បត្តិនឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេស ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជី ព្រមទាំងពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ ការអនុវត្តការងារទាន់ពេលវេលា និង កិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការជាមួយម្ចាស់គម្រោងដោយផ្អែកលើកំណត់ត្រាកន្លងមក ។លទ្ធផលនៃការវាយតម្លៃនេះ អនុគណៈកម្មការបុរេលក្ខណសម្បត្តិ នឹងដាក់ជូន ឯកឧត្តមអភិបាលខេត្ត ដើម្បីពិនិត្យនិងសម្រេច។អ្នកទទួលការទាំងឡាយណាដែលត្រូវ បានរកឃើញថា មានការពាក់ព័ន្ធនឹងការឃុបឃិតគ្នា ការក្លែងបន្លំ និងអំពើពុករលួយ ហើយចាប់ពីពេលដែលត្រូវបានដកសិទ្ធិជាផ្លូវការអ្នកទទួលការនោះនឹងមិនត្រូវបានពិចារណាក្នុងការបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកទទួលការឡើយ។

អាស្រ័យហេតុនេះ បើអ្នកទទួលការមានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ សូមរួសរាន់មកដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅទីចាត់ការផែនការនិងវិនិយោគ សាលាខេត្តស្វាយរៀង (រៀងរាល់ម៉ោងធ្វើការ) ចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី២៦ខែតុលា ឆ្នាំ២០២០ វេលាម៉ោង៥ល្ងាចបញ្ចប់ការទទួលពាក្យ។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមកក៏ត្រូវដាក់ពាក្យ សុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការជាថ្មីឡើងវិញដែរ។

អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ នៅការិយាល័យគាំទ្រមូលដ្ឋាន នៃទីចាត់ការផែនការនិងវិនិយោគ សាលាខេត្តស្វាយរៀង ឬអាចទាញយកពីគេហទំព័ររបស់គ.ជ.អ.ប(http://ncdd.gov.kh) ដោយឥតបង់ថ្លៃ។៚

**អភិបាលខេត្តស្វាយរៀង**

**ម៉ែន_វិបុល**